# ២. បញ្ចូលសិទ្ធិមនុស្សនៅក្នុងវិស័យអប់រំ ៖ ត្រូវបញ្ចូលអ្វីខ្លះ និងដោយរបៀបណា

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋ សិទ្ធិវប្បធម៌ សង្គមកិច្ច និងសិទ្ធិសេដ្ឋកិច្ច ជាមួយនឹងសេចក្តីប្រកាសសកលស្តីពីសិទ្ធិមនុស្សត្រូវបានប្រកាសដោយអង្គការសហប្រជាជាតិឲ្យបង្កើតសន្ធិសញ្ញាសំខាន់ៗ ដែលរួមមានច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស។ សន្ធិសញ្ញាអន្តរជាតិសំខាន់បីបន្ថែមទៀតអាចធ្វើជាខ្នាតគំរូសំរាប់វាស់វែងការខិតខំប្រឹងប្រែងឆ្ពោះទៅសំរេចគោលដៅនៃការអប់រំសំរាប់ទាំងអស់គ្នា និងជាពិសេសដើម្បីលុបបំបាត់ការរើសអើងនៅក្នុងវិស័យអប់រំ។ សន្ធិសញ្ញាទាំងបីនេះគឺអនុសញ្ញាយូណេស្កូប្រឆាំងនឹងការរើសអើងនៅក្នុងការអប់រំ អនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍ និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី។

សន្ធិសញ្ញាចុងក្រោយផ្តោតលើការលុបបំបាត់វិសមភាពយេនឌ័រគិតជាតួលេខប្រៀបធៀបនៅក្នុងពេល វេលាមួយដែលគេបានព្រមព្រៀងគ្នានៅក្នុងក្របខ័ណ្ឌសម្មភាពក្រុងដាកា។ គោលដៅទាំង ៦ របស់ការអប់រំសំរាប់ទាំងអស់គ្នាពង្រីកទៅដល់ការអប់រំកុមារតូច មនុស្សជំទង់ និងមនុស្សចាស់ ក៏ប៉ុន្តែអ្នកដែលទទួលការយកចិត្តទុកដាក់ជាសកលនោះគឺកុមារ និងលើអនុសញ្ញាស្តីពីសិទ្ធិកុមារ។ អនុសញ្ញានេះដែលត្រូវបានផ្តល់សច្ចាប័នដោយប្រទេសចំនួន ១៩២ គិតត្រឹមខែធ្នូ ឆ្នាំ ២០០៣ គឺជាអនុសញ្ញាសំរាប់ណែនាំ និងជំរាបពីការខិតខំប្រឹងប្រែងជាសកលសំរាប់បង្កើនឱកាសចូលរៀនរបស់កុមារ និងឲ្យនិយមន័យសំគាល់គ្រប់សិទ្ធិកុមារទាំងអស់ ពីព្រោះថាសិទ្ធិទាំងអស់នេះនឹងត្រូវបានគេយកទៅអនុវត្តនៅក្នុងការអប់រំ។

ជាទីបញ្ចប់ ទំនាក់ទំនងរវាងការអប់រំ និងការលុបបំបាត់ភាពក្រីក្រ និងជាពិសេសការលុបបំបាត់ពលកម្មកុមារត្រូវបានសង្កត់ធ្ងន់ដោយសន្ធិសញ្ញាអន្តរជាតិធំៗពីរដែលរៀបចំដោយអង្គការពលកម្មពិភពលោក ពោលគឺអនុសញ្ញាស្តីពីអាយុអប្បបរមាសំរាប់បំពេញការងារ និងអនុសញ្ញាស្តីពីពលកម្មកុមារអាក្រក់បំផុត។

សិទ្ធិទទួលការអប់រំត្រូវបានបញ្ជាក់ច្បាស់នៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗចំនួន ៥ ដែលបានបង្ហាញនៅក្នុងតារាងទី ១ ដោយមានបញ្ចូលទាំងចំនួនរដ្ឋដែលបានផ្តល់សច្ចាប័នរួចហើយ គិតមកត្រឹមខែធ្នូ ឆ្នាំ ២០០៣។ តារាងនេះបង្ហាញថា រដ្ឋទាំងអស់នៅក្នុងពិភពលោកគឺយ៉ាងហោចណាស់ ក៏ជាភាគីមួយនៅក្នុងសន្ធិសញ្ញាណាមួយដែរ នៅក្នុងចំណោមសន្ធិសញ្ញាទាំង ៥ នេះ។ សន្ធិសញ្ញានេះកំណត់ផ្នែកផ្សេងៗនៃសិទ្ធិទទួលការអប់រំ ដូចជា សិទ្ធិវប្បធម៌ សង្គម សេដ្ឋកិច្ច នយោបាយ និងសិទ្ធិពលរដ្ឋ ព្រមទាំងមានបញ្ជាក់អំពីសិទ្ធិរបស់កុមារម្នាក់ៗទៀតផង។

ចំនួនរដ្ឋជាច្រើន ដែលជាភាគីរបស់សន្ធិសញ្ញានេះបង្ហាញពីការទទួលយកជាសកល។ អនុសញ្ញាស្តីសិទ្ធិកុមារបានទទួលសច្ចាប័នដោយប្រទេសចំនួន ១៩២។ ការលើកលែងមានតែសហរដ្ឋអាមេរិក និងសូម៉ាលីប៉ុណ្ណោះ។ ចំនួនតិចជាងនេះបន្តិច (២ ភាគ ៣ នៃពិភពលោក) ផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិវប្បធម៌ សង្គមកិច្ច និងសិទ្ធិសេដ្ឋកិច្ច។ ព័ត៌មានស្តីពីថា តើរដ្ឋនីមួយៗប្តេជ្ញាចិត្តចំពោះសន្ធិសញ្ញាទាំងនេះយ៉ាងណានោះមាននៅក្នុងរបាយការណ៍រដ្ឋាភិបាលដែលសន្ធិសញ្ញាទាំង ៥ នេះតម្រូវឲ្យរដ្ឋាភិបាលនីមួយៗផ្តល់របាយការណ៍ម្តងម្កាលស្តីពីវិធានការអនុវត្តជាក់ស្តែងដើម្បីការពារសិទ្ធិមនុស្សរួមបញ្ចូលទាំងសិទ្ធិទទួលការអប់រំផងដែរ។

**តារាងទី ១ : សន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗ និងចំនួនរដ្ឋដែលជាភាគីនៃសន្ធិសញ្ញាទាំងនេះ**

| សន្ធិសញ្ញា | អក្សរកាត់ | អនុម័តនៅឆ្នាំ | ចូលជាធរមាន | ភាគីរដ្ឋ |
|---|---|---|---|---|
| កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋ | ICCPR | ១៩៦៦ | ១៩៧៦ | ១៥១ |
| កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិវប្បធម សង្គមកិច្ច និងសេដ្ឋកិច្ច | ICESCR | ១៩៦៦ | ១៩៧៦ | ១៤៨ |
| អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ | AICERD | ១៩៦៥ | ១៩៦៩ | ១៦៩ |
| អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើបប្រឆាំងនឹងស្ត្រី | CEDAW | ១៩៧៩ | ១៩៨១ | ១៧៤ |
| អនុសញ្ញាស្តីពីសិទ្ធិកុមារ | CRC | ១៩៨៩ | ១៩៩០ | ១៩២ |

តារាងនេះបង្ហាញថា រដ្ឋទាំងអស់ពុំទាន់បានផ្តល់សច្ចាប័នឲ្យសន្ធិសញ្ញាទាំងអស់នៅឡើយទេ។ នៅពេលដែលសន្ធិសញ្ញាត្រូវបានផ្តល់សច្ចាប័ន សន្ធិសញ្ញាទាំងនោះត្រូវបានកំហិតសំរាប់ការអនុវត្តដាក់ស្តែងនៅក្នុងប្រទេសនីមួយៗ។ លើសពីនេះទៀត សន្ធិសញ្ញាអន្តរជាតិមិនត្រូវបានយកមកអនុវត្តដោយផ្ទាល់ទេនៅតាមបណ្តាប្រទេសជាច្រើន ប៉ុន្តែប្រទេសមួយចំនួនបានកែប្រែច្បាប់ទាំងនេះឲ្យទៅជាច្បាប់ប្រទេស។ ដោយផ្អែកលើសន្ធិសញ្ញានេះប្រទេសនានាអាចបង្កើតយុទ្ធសាស្ត្រអប់រំបាន។

ដើម្បីធ្វើឲ្យប្រព័ន្ធអប់រំមានមូលដ្ឋាន លើគោលការណ៍ដែលទទួលយកបានជាអន្តរជាតិនៃសិទ្ធិមនុស្ស គេត្រូវការយុទ្ធសាស្ត្ររួមដែលគ្របដណ្តប់លើប្រព័ន្ធអប់រំទាំងមូល។ គុណប្រយោជន៍នៃការអប់រំដោយផ្អែកលើសិទ្ធិនៅវែងឆ្ងាយណាស់ ការអប់រំមានទំនាក់ទំនងជាមួយនឹងសិទ្ធិមនុស្សផ្សេងទៀត និងសេរីភាពមូលដ្ឋានដូចជា សិទ្ធិក្នុងការបំពេញការងារដែលមានតួនាទីដ៏សំខាន់ក្នុងការលុបបំបាត់ភាពក្រីក្រ សិទ្ធិក្នុងការរៀបការ និងមានគ្រួសារដែលមានឥទ្ធិពលលើបំរែបំរួលប្រជាសាស្ត្រ និងសិទ្ធិក្នុងការចូលរួមនៅក្នុងនយោបាយដែលបញ្ជាក់អំពីសារៈសំខាន់នៃការអប់រំសំរាប់កសាសសង្គមមួយដែលមានលក្ខណៈរួមបញ្ចូលគ្នាទាំងអស់។

**សន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗ**

ភាគីរដ្ឋនីមួយៗនៅក្នុងសន្ធិសញ្ញាណាមួយនៃសន្ធិសញ្ញាទាំង ៥ ដែលមានបង្ហាញនៅក្នុងតារាង ទី ១ ត្រូវដាក់របាយការណ៍មួយម្កាលដើម្បីបង្ហាញពីស្ថានភាពនៃការអនុវត្តសន្ធិសញ្ញាទាំងនោះ។ របាយការណ៍អំពីការរីកចំរើនទាំងនេះដែលរៀបចំឡើងដោយរដ្ឋាភិបាលនីមួយៗគឺជាការវាយតម្លៃដោយខ្លួនឯងថា តើរដ្ឋាភិបាលនីមួយៗបានបំពេញភារកិច្ចសិទ្ធិមនុស្សអន្តរជាតិដល់ណាហើយនៅក្នុងការអប់រំ។ ដំណើរការធ្វើរបាយការណ៍នៃសិទ្ធិសញ្ញាទាំង ៥ នៅពេលតំណាលគ្នា បង្កើតឲ្យមានឯកសារយ៉ាងច្រើនសន្ធឹកសន្ធាប់។ គុណសម្បត្តិមួយគឺថាឥឡូវនេះ គេមានព័ត៌មានយ៉ាងច្រើនស្តីពីការខិតខំប្រឹងប្រែងជាសកលដើម្បីប្រែក្លាយការអប់រំដោយផ្អែកលើសិទ្ធិឲ្យទៅជាការពិត។

ចំណែកឯគុណវិបត្តិគឺថាព័ត៌មានមួយចំនួនជាព័ត៌មានដដែលៗ ពីព្រោះសិទ្ធិទទួលការអប់រំត្រូវបានលើកឡើងនៅក្នុងសន្ធិសញ្ញាទាំង ៥។ លើសពីនេះទៀត ការរៀបចំរបាយការណ៍មួយម្កាលសំរាប់សន្ធិសញ្ញានីមួយៗ គឺជាដំណើរការដែលត្រូវការធនធានយ៉ាងច្រើន ទាំងសំរាប់រដ្ឋាភិបាលនីមួយៗ ទាំងអង្គការសហប្រជាជាតិ។ ដោយហេតុនេះ អគ្គលេខាធិការអង្គការសហប្រជាជាតិបានសុំឲ្យមានការផ្តួចផ្តើមគំនិតដែលមានគោលបំណង

ធ្វើឲ្យការធ្វើរបាយការណ៍នេះស្រួល និងឯកភាពគ្នាលើចំណុចមួយចំនួន។ ឯកសារនេះយកតាមការផ្ដួចផ្ដើមគំនិតនេះ ហើយបង្ហាញតួនាទីសិទ្ធិមនុស្សដែលទាក់ទងនឹងការអប់រំតាមរយៈគម្រោងដែលមានបញ្ញត្តិសំខាន់ៗនៃសន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗ។

## ២.១. ក្របខ័ណ្ឌផ្លូវច្បាប់

ក្របខ័ណ្ឌផ្លូវច្បាប់របស់រដ្ឋាភិបាលដែលកើតចេញពីសិទ្ធិទទួលការអប់រំអាចនឹងត្រូវគេរៀបចំឲ្យងាយស្រួលតាមរយៈគម្រោងទាំង ៤ ដូចខាងក្រោម :

- **ធនធានរូបវ័ន្ត** និយាយពីភារកិច្ច ៣ យ៉ាងរបស់រដ្ឋាភិបាល : ការអប់រំគឺជាសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយទាមទារឲ្យរដ្ឋាភិបាលអនុញ្ញាតឲ្យមានការបង្កើតសាលា ដោយគោរពសេរីភាពក្នុងការអប់រំ។ ការអប់រំគឺជាសិទ្ធិសង្គមកិច្ច និងសេដ្ឋកិច្ចទាមទារឲ្យរដ្ឋាភិបាលធានាឲ្យមានការអប់រំដោយខានមិនបាន និងមិនគិតថ្លៃសំរាប់កុមារគ្រប់អាយុចូលរៀនទាំងអស់។ ការអប់រំគឺជាសិទ្ធិវប្បធម៌ទាមទារឲ្យមានការគោរពដល់សិទ្ធិជនជាតិភាគតិច និងជនជាតិដើម។

- **ឱកាសចូលរៀន** មានន័យថារដ្ឋាភិបាលត្រូវតែខិតខំប្រឹងប្រែងក្នុងការលុបបំបាត់ការរើសអើងយេនឌ័រ និងពូជសាសន៍ និងធានាឲ្យមានការរីករាយស្មើភាពគ្នានៃរាល់សិទ្ធិមនុស្សទាំងអស់។ ការលុបបំបាត់ត្រូវធ្វើឲ្យមានជាក់ស្ដែង មិនមែនគ្រាន់តែជាការហាមឃាត់មិនឲ្យមានជាផ្លូវការនៅក្នុងក្រដាសនោះទេ។ លើសពីនេះទៀត ឱកាសចូលរៀនទាក់ទងនឹងកំរិតសិក្សាផ្សេងគ្នា ដូចជា បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា។ រដ្ឋាភិបាលត្រូវធានាផ្ដល់ការអប់រំដោយខានមិនបាន និងមិនគិតថ្លៃដល់កុមារទាំងអស់ដែលនៅក្នុងអាយុគ្រប់វ័យសិក្សាដោយខានមិនបាន។ ការអប់រំដោយខានមិនបានត្រូវធ្វើឲ្យបានឆាប់រហ័ស និងបង្កលក្ខណៈឲ្យកុមាររៀនទៅមធ្យមសិក្សាតាមកាលៈទេសៈជាក់ស្ដែង។

- **គុណភាពអប់រំដែលអាចទទួលយកបាន** ទាមទារការធានាអប្បបរមាទាក់ទងនឹងគុណភាពអប់រំដូចជាផ្នែកអនាម័យ និងសុវត្ថិភាព ឬកំរិតវប្បធម៌អាជីពរបស់គ្រូបង្រៀន។ ការពិតទៅ គុណភាពអប់រំមានន័យទូលំទូលាយជាងនេះច្រើនណាស់។ ការធានាទាំងនេះត្រូវតែកំណត់ឲ្យបានច្បាស់លាស់ តាមដាន និងពង្រឹងដោយរដ្ឋាភិបាល តាមរយៈប្រព័ន្ធអប់រំ ទោះជាស្ថាប័នអប់រំជារបស់រដ្ឋ ឬឯកជនក៏ដោយ។ គុណភាពអប់រំអាចទទួលយកបានមានន័យទូលំទូលាយណាស់តាមរយៈការបង្កើតច្បាប់សិទ្ធិមនុស្សអន្តរជាតិ សិទ្ធិរបស់ជនជាតិភាគតិច និង ជនជាតិដើមត្រូវផ្ដល់អាទិភាពដល់ភាសាយានក្នុងការបង្រៀននៅពេលដែលការហាមឃាត់មិនឲ្យមានការដាក់ទណ្ឌកម្មលើរាងកាយ និងវិន័យសាលា។ ការចាត់ទុកកុមារថាជាវត្ថុដែលត្រូវទទួលការអប់រំ និងសិទ្ធិទទួលការអប់រំត្រូវបានបង្កើនឲ្យហួសព្រំដែននៃគុណភាពអប់រំដែលអាចទទួលយកបានដោយបញ្ចូលខ្លឹមសារនៃកម្មវិធីអប់រំ និងសៀវភៅសិក្សាដែលត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំងពីទស្សនៈសិទ្ធិមនុស្ស។

- **ការកែសម្រួលតាមតម្រូវការ** ទាមទារឲ្យសាលាឆ្លើយតបទៅនឹងតម្រូវការរបស់កុមារម្នាក់ៗ ដោយផ្សារភ្ជាប់ជាមួយនឹងអនុសញ្ញាស្ដីពីសិទ្ធិកុមារ។ ការទាមទារនេះផ្ទុយទៅនឹងទំលាប់ចាស់ ដែលទាមទារឲ្យកុមារកែប្រែទៅតាមអ្វីដែលសាលាផ្ដល់ឲ្យ។ ដោយហេតុថា សិទ្ធិមនុស្សមិនមែននៅដាច់តែឯង នោះការកែប្រែតាមតម្រូវការទាក់ទងនឹងការការពារសិទ្ធិមនុស្សនៅក្នុងការអប់រំ ក៏ដូចជាការពង្រឹងសិទ្ធិមនុស្សតាមរយៈការអប់រំ។ ការងារនេះតម្រូវឲ្យមានការវិភាគឲ្យបានគ្រប់ជ្រុងជ្រោយនូវរាល់ឥទ្ធិពលអប់រំលើសិទ្ធិមនុស្សដើម្បីតាមដាន ការមានការងារធ្វើ របស់អ្នករៀនចប់ ដោយធានាឲ្យមានការធ្វើផែនការជាមួយផ្នែកពាក់ព័ន្ធ។

តារាងទី ២ ខាងក្រោមរៀបរាប់ពីតម្រូវការសិទ្ធិមនុស្សដែលផ្អែកទីមួយៗនៃផ្នែកទាំង ៤ ខាងដើម។

## កាតព្វកិច្ច របស់រដ្ឋាភិបាល

ដើម្បីឲ្យការអប់រំក្លាយជាសិទ្ធិមនុស្សសកលដែលគួរឲ្យសរសើរនោះ កាតព្វកិច្ចរបស់រដ្ឋាភិបាលក៏ត្រូវមានលក្ខណៈសកលដែរ។ ដូច្នេះ កិច្ចសហប្រតិបត្តិការអន្តរជាតិគឺជាវិធានការសំខាន់សំរាប់សម្រួលដល់ដំណើរឆ្ពោះទៅសំរេចការអប់រំផ្អែកលើសិទ្ធិមនុស្សនៅក្នុងប្រទេស ដែលរដ្ឋាភិបាលពុំទាន់មានសមត្ថភាពអប្បបរមាផ្តល់ការអប់រំដល់កុមារគ្រប់រូបនៅឡើយ។ ព័ត៌មានស្ថិតិអប់រំបង្ហាញថា កុមារគ្រប់រូបពុំទាន់បានទទួលការអប់រំដែលមានគុណភាពដូចគ្នា ឬមានឱកាសបានរៀនដូចគ្នានោះទេ។ ជំហានដំបូងនៃការលុបបំបាត់ការរើសអើង ឬការបាត់បង់ឱកាសចូលរៀន គឺការលើកយកបញ្ហាទាំងនេះមកបកស្រាយដោយចំហរ។ ការលាក់ទុកបញ្ហាមិនយកមកពិភាក្សា នឹងបង្កឲ្យមានបញ្ហាកាន់តែធ្ងន់ធ្ងរទៅៗ ដូចជាវិសមភាពដែលចេះតែកើតមានបន្តពីមួយជំនាន់ទៅមួយជំនាន់។

**តារាងទី ២ : កាតព្វកិច្ចសិទ្ធិមនុស្សសំខាន់នៅក្នុងការអប់រំ**

| | |
|---|---|
| ធនធានរូបវន្ត | កាតព្វកិច្ចផ្តល់ការអប់រំដោយខានមិនបាននិងមិនគិតថ្លៃសំរាប់កុមារគ្រប់រូបតាមអាយុកំណត់ចូលរៀននិងរហូតដល់អាយុដែលអាចធ្វើការបាន។ |
| | កាតព្វកិច្ចក្នុងការគោរពសិទ្ធិរបស់ឪពុកម្តាយក្នុងការជ្រើសរើសការអប់រំសំរាប់កូនរៀនដោយមិនភ្លេចពិនិត្យមើលពីផលប្រយោជន៏របស់កុមារឡើយ។ |
| ឱកាសបានចូលរៀន | កាតព្វកិច្ចក្នុងការលុបបំបាត់ការបាត់បង់ឱកាសចូលរៀន ដោយផ្អែកលើមូលដ្ឋាននៃការរើសអើងដែលត្រូវបានគេហាមឃាត់ជាអន្តរជាតិ (ជនជាតិ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិយោបល់ ស្ថានភាពសេដ្ឋកិច្ច សញ្ជាតិ ឋានៈសង្គម ជនជាតិភាគតិច ជនជាតិដើម និងពិការភាព)។ |
| | កាតព្វកិច្ចក្នុងការលុបបំបាត់ការរើសអើងយេនឌ័រ និងសញ្ជាតិដោយធានាឲ្យគេទទួលបានផលប្រយោជន៏ពីសិទ្ធិមនុស្សដូចគ្នានៅក្នុងការអនុវត្តជាក់ស្តែងជាជាងគ្រាន់តែជាការសន្យាជាផ្លូវការ។ |
| គុណភាពដែលអាចទទួលយកបាន | កាតព្វកិច្ចក្នុងការកំណត់ស្តង់ដាអប្បបរមាសំរាប់ការអប់រំរួមបញ្ចូលទាំងភាសាយានក្នុងការបង្រៀន ខ្លឹមសារ និងវិធីសាស្ត្របង្រៀន និងធានាឲ្យមានការអនុវត្តតាមស្តង់ដានេះនៅក្នុងស្ថាប័នអប់រំទាំងអស់។ |
| | ការសម្របសម្រួល តាមតម្រូវការ កាតព្វកិច្ចក្នុងការរៀបចំ និងអនុវត្តការអប់រំសំរាប់កុមារដែលនៅក្រៅសាលាចំណេះទូទៅ (ជនភៀសខ្លួន ឬ ជនផ្លាស់ទីលំនៅ កុមារដែលបាត់បង់សេរីភាព និងកុមារដែលធ្វើការ)។ |
| កែសម្រួលឲ្យស្របតាមតម្រូវការជាក់ស្តែង | កាតព្វកិច្ចកែសម្រួលការអប់រំដើម្បីបំរើផលប្រយោជន៏ដល់កុមារម្នាក់ៗ ជាពិសេស កុមារពិការ ជនជាតិភាគតិច និងជនជាតិដើម។ |
| | កាតព្វកិច្ចក្នុងការរក្សាឲ្យបាននូវការមិនបែងចែកសិទ្ធិមនុស្សឲ្យទៅជាឯកសារផ្សេងគ្នាដូចជាការបែងចែកសិទ្ធិក្នុងការរៀបការ និងមានគ្រួសារ ឬសិទ្ធិទទួលសេរីភាពចាកផុតពីពលកម្មកុមារ និងពលកម្មដោយបង្ខំនោះទេ។ |

វាមានលក្ខណៈសំខាន់ណាស់ក្នុងការកត់សំគាល់ពីភាពក្រីក្រដែលបណ្តាលមកពីការបដិសេធសិទ្ធិ និងការរំលោភសិទ្ធិមនុស្ស។ កុមារី និងស្ត្រីជាអ្នកដែលតែងរកប្រាក់ចំណូលបានតិចដោយសារការរំលោភសិទ្ធិមនុស្ស។ នៅប្រទេសជាច្រើន កុមារី និងស្ត្រីជាអ្នកដែលគេបដិសេធមិនឲ្យទទួលមត៌កដីធ្លី មិនឲ្យរកស៊ីដោយខ្លួនឯង និងមិនឲ្យមានគណនី ធនាគារដោយខ្លួនឯង។ ការកែទម្រង់ច្បាប់ និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ជាវិធានការចាំបាច់ដើម្បីធានាផ្តល់សិទ្ធិស្មើភាពសំរាប់ទាំងអស់គ្នាដែលសកម្មភាពទាំងនេះគួរតែទទួលប្រាក់ឧត្ថម្ភ។

ជាសំខាន់ជាងនេះទៀត ដំណើរការនៃការធ្វើវិមជ្ឈការអាចនាំឲ្យមានវិសមភាពនៅក្នុងឱកាសចូលរៀនដោយការផ្តល់ហិរញ្ញវត្ថុដល់ការអប់រំគឺជាការទទួលខុសត្រូវរបស់អ្នកក្រ និងប្រជាជនមូលដ្ឋាន។ នៅពេលដែលការអប់រំត្រូវទទួលការផ្គត់ផ្គង់ដោយមូលដ្ឋាន នោះគម្លាតរវាងអ្នកមាន និងអ្នកក្រកាន់តែ ធំឡើងៗដោយហេតុថាសហគមន៏ក្រីក្រមិនអាចមានលទ្ធភាពផ្តល់ហិរញ្ញវត្ថុឲ្យបានដូចសហគមន៏អ្នកមានទេ។ លុបបំបាត់ស្ថានភាពវិលវល់បែបនេះទាមទារឲ្យរដ្ឋាភិបាលនីមួយៗ ឬរួមគ្នាទាំងមូលដ្ឋាន ឬថ្នាក់ជាតិផ្តល់លទ្ធភាពក្នុងការគាំទ្រការអប់រំ និង ធានាឲ្យមានការបែងចែកថវិកាឲ្យស្មើភាពគ្នា។ ធានាឲ្យមានការអនុវត្តជាក់ស្តែងនូវសិទ្ធិទទួលការអប់រំជាសកលទាមទារឲ្យមានកាតព្វកិច្ចជាសកលរបស់រដ្ឋាភិបាលផងដែរ។

ជាគោលការណ៍ សិទ្ធិទទួលការអប់រំទាក់ទង តួអង្គសំខាន់ៗបី គឺរដ្ឋាភិបាលក្នុងនាមជាអ្នកផ្តល់ ការអប់រំ និង/ឬជាអ្នកផ្តល់ថវិកាដល់សាលារដ្ឋ កុមារជាអ្នកមានសិទ្ធិទទួលការអប់រំ និងភារកិច្ចបំពេញការអប់រំដោយខានមិនបាន និងឪពុកម្តាយសិស្សដែលជាគ្រូដំបូងគេ។ តួអង្គក្រោយគេនៃតួងអង្គទាំងបីនេះគឺជាអ្នកមានសេរីភាពក្នុងការជ្រើសរើសការអប់រំសំរាប់ កូនរៀន។ ប៉ុន្តែត្រូវយល់ឲ្យច្បាស់ថា ការជ្រើសរើសរបស់ឪពុកម្តាយគឺជាការរំលោភច្បាប់ បើសិនជាឪពុកម្តាយបដិសេធមិនឲ្យកូនចូលរៀនដោយសារតែមានទំនាស់រវាងការជ្រើសរើសរបស់ឪពុកម្តាយ និងផលប្រយោជន៍របស់កុមារ។ ក្នុងករណីនេះ គេត្រូវផ្តល់អាទិភាពដល់កុមារ។ ដើម្បីចៀសវាងបញ្ហានេះ រដ្ឋមិនត្រូវផ្តាច់មុខក្នុងការផ្តល់ការអប់រំទេ រដ្ឋត្រូវធ្វើយ៉ាងណាឲ្យមានការអប់រំច្រើនប្រភេទច្រើនសណ្ឋាន។

## ២.២. កុមារគឺជាអ្នកដែលមានអាទិភាពមានសិទ្ធិទទួលការអប់រំ

នៅពេលដែលសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងអស់សង្កត់ធ្ងន់លើសិទ្ធិទទួលការអប់រំដោយមិនគិតពីអាយុ អាទិភាពពិតប្រាកដត្រូវផ្តល់ឲ្យកុមារ ហើយរដ្ឋាភិបាលមានភារកិច្ចផ្តល់ការអប់រំដោយមិនគិតថ្លៃ និងដោយខានមិនបានដល់កុមារគ្រប់រូប។

***សិទ្ធិកុមារ***

ទំនាក់ទំនងរវាងអនុសញ្ញាសិទ្ធិមនុស្សនឹងកុមារដែលមានគោលបំណងធានាមិនឲ្យមានការរំលោភបំពាននៃអំណាចរដ្ឋក៏មាននិយាយយ៉ាងច្បាស់អំពីកាតព្វកិច្ចរបស់មនុស្សពេញវ័យ ហើយជាពិសេសបានកំណត់ការទទួលខុសត្រូវរបស់ឪពុកម្តាយ។ កាតព្វកិច្ចរបស់ឪពុកម្តាយទាក់ទងនឹងការអប់រំកូនត្រូវបំពេញបន្ថែមដោយការហាមឃាត់ជាច្រើនប្រឆាំងនឹងការរំលោភបំពាន និងការកេងប្រវ័ញ្ច។ រដ្ឋាភិបាលទទួលខុសត្រូវបង្កើតលក្ខខណ្ឌដែលគាំទ្រឲ្យមានការគោរពសិទ្ធិកុមារពេញលេញ ដែលរួមបញ្ចូលទាំងការទទួលខុសត្រូវរបស់ឪពុកម្តាយចំពោះកូនផងដែរ។ រដ្ឋាភិបាលត្រូវធានាផងដែរថា មនុស្សពេញវ័យទាំងអស់ត្រូវបំពេញតួនាទីពលរដ្ឋដូចជា ការបង់ពន្ធ ដែលប្រាក់ពន្ធនេះអាចយកទៅប្រើប្រាស់ក្នុងការចាយវាយនៅក្នុងវិស័យអប់រំ។

***ការកំណត់អាយុអប្បបរមា***

ការពន្យល់ពីភាពចាំបាច់នៃការអប់រំផ្អែកលើសិទ្ធិមនុស្សមានចែងនៅក្នុងតារាងទី ៣ ដែលបង្ហាញពីភាពខុសគ្នានៃសិទ្ធិដែលផ្អែកលើអាយុរបស់កុមារ នៅក្នុងប្រទេសអាស៊ីមួយចំនួន។ ទិន្នន័យត្រូវបានប្រមូលពីរបាយការណ៍របស់រដ្ឋាភិបាលនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ មានតែប្រទេសអាស៊ីប៉ុណ្ណោះដែលរបាយការណ៍ត្រូវបានយកមកពិចារណាដោយគណៈកម្មការសិទិកុមារ និងដាក់បញ្ចូលនៅក្នុងតារាងនេះ។ តួលេខបង្ហាញថា នៅក្នុងប្រទេសមួយចំនួន ដូចជា វៀតណាម កុមារអាចបញ្ចប់ការសិក្សានៅអាយុត្រឹម ១០ ឆ្នាំ ហើយកុមារទាំងនេះមិនត្រូវបានអនុញ្ញាតឲ្យធ្វើការទេ រហូតដល់គេមានអាយុ ១៥ ឆ្នាំ។

នៅក្នុងប្រទេសជាច្រើនទៀត កុមារមិនត្រូវបានទទួលស្គាល់ថាមានសិទ្ធិស្មើគ្នាទេ ឬមានតួទីឋានៈក្នុងការប្តឹងផ្តល់ប្រឆាំងនឹងការបដិសេធសិទ្ធិ ឬការរំលោភសិទ្ធិទេ។ ដោយហេតុផលនេះ មានតួអង្គពាក់ព័ន្ធមួយចំនួនត្រូវធ្វើការជាមួយគ្នាដើម្បីធានាឲ្យមានការគោរពសិទ្ធិកុមារ ដែលតួអង្គទាំងនេះរួមមានឪពុកម្តាយ គ្រូ និងស្ថាប័នជំនាញ ដូចជា អង្គការទទួលពាក្យបណ្តឹងរបស់កុមារ។ ការបញ្ចូលឲ្យមានតួអង្គច្រើនបែបនេះគឺដើម្បីជំរុញឲ្យមានយុត្តិធម៌សំរាប់កុមារ និងផ្អែកលើមូលដ្ឋាន បីយ៉ាងរបស់សិទ្ធិកុមារ :

**តារាងទី ៣ : តម្រូវការសំរាប់គោលនយោបាយសិទ្ធិកុមារ ដែលបញ្ជាក់ដោយច្បាប់អាយុអប្បបរមា**[៥]

| | | | | |
|---|---|---|---|---|
| បង់ក្លាដែស | ១០ | ១៤ | ១៨ /១៨ | ៧ |
| ព្រុយណេ | មិនកាតព្វកិច្ច | ១៤ | គ្មានអប្បបរមា | ៧ |
| កម្ពុជា | គ្មានអប្បបរមា | ១៦ | ១៨/២០ | គ្មានអប្បបរមា |
| ហ្វីជី | គ្មានអប្បបរមា | ១២ | ១៦/១៨ | ១០ |
| ឥណ្ឌា | ១៤ | ១៤ | មានច្រើនទម្រង់ | ១២ |
| ឥណ្ឌូណេស៊ី | ១៥ | ១៥ | គ្មានអប្បបរមា | ៨ |
| ជប៉ុន | ១៥ | ១៥ | ១៦/១៨ | ១៤ |
| ឡាវ | ១០ | ១៥ | ១៥ | ១៥ |
| មីយ៉ាន់ម៉ា | គ្មានអប្បបរមា | គ្មានអប្បបរមា | គ្មានអប្បបរមា | ៧ |
| ប៉ាគីស្ថាន | មិនកាតព្វកិច្ច | ១៤ | គ្មានអប្បបរមា | ៧ |
| ប៉ាពួញូហ្គីនី | មិនកាតព្វកិច្ច | ១៤ | គ្មានអប្បបរមា | ៧ |
| ហ្វីលីពីន | ១២ | ១៥ | N/A | ៧ |
| សាធារ.កូរេ | ១៥ | ១៥ | ១៦/១៨ | ១៤ |
| សឹង្ហបូរី | ១៦ | មានច្រើនទម្រង់ | N/A | ៧ |
| កោះសូឡូម៉ុង | មិនកាតព្វកិច្ច | ១២ | ១៥ | ៨ |
| ស្រីលង្កា | ១៤ | ១០ | គ្មានអប្បបរមា | ៨ |
| ថៃ | ១៦ | ១៣ | ១៧ | ៧ |
| វៀតណាម | ១០ | ១៥ | ១៨/២០ | ១៤ |

**ប្រភព : របាយការណ៍របស់រដ្ឋាភិបាលស្តីពីសិទ្ធិកុមារ**

១. ការទទួលស្គាល់សិទ្ធិកុមារចាំបាច់ឲ្យអាជ្ញាធរសាធារណៈ ឪពុកម្តាយ និងគ្រួសារព្រមទាំងមនុស្សពេញវ័យគ្រប់រូបបំពេញកាតព្វកិច្ច និងភារកិច្ចជាក់លាក់។ សក្តានុភាពនៃការរំលោភបំពានលើកុមារទាមទារឲ្យមានការបង្កើតស្ថាប័នពិសេសសំរាប់កុមារ និងការពារសិទ្ធិកុមារ។

២. សិទ្ធិកុមារត្រូវមានលើសពីប្រព័ន្ធច្បាប់ ហើយទាក់ទងនឹងអាជ្ញាធរ និង គោលនយោបាយសាធារណៈ ពីព្រោះដំណើរការម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធអាចធ្វើឲ្យកម្មវិធី និងគម្រោងនៅកំរិតមីក្រូកាន់តែជួបការលំបាក។ ការគិតគូរពីឥទ្ធិពលនៃគោលនយោបាយលើកុមារគឺជាការចាំបាច់ដើម្បីចៀសវាងផលប៉ះពាល់ផ្សេងៗដល់កុមារដែលអាចកើតមានដោយថាហេតុ។

៣. កុមារខ្វះចំណេះដឹង បទពិសោធន៏ និងសំលេងនយោបាយដែលចាំបាច់សំរាប់ការពារសិទ្ធិ។ ភាពអសកម្មផ្នែកច្បាប់ និងការពឹងពាក់ផ្នែកលើហិរញ្ញវត្ថុរបស់មនុស្សពេញវ័យរារាំងកុមារមិនឲ្យប្រើប្រាស់ យន្តការច្បាប់ដែលមានស្រាប់ដើម្បីការពារសិទ្ធិ។ ដូច្នេះ អង្គការគាំពារកុមារពិគ្រោះយោបល់សំរាប់កុមារ និងទទួលពាក្យបណ្តឹងរបស់កុមារគឺជាអង្គភាពចាំបាច់ដើម្បីជួយកុមារ។

ស្ថាប័នជាច្រើនដែលមានលក្ខណៈបែបនេះត្រូវបានបង្កើតឡើងនៅប្រទេសជាច្រើន ទោះជាការងាររបស់អង្គភាពនេះមួយចំនួនជាន់គ្នានឹងការទទួលខុសត្រូវរបស់ភ្នាក់ងាររដ្ឋាភិបាលក៏ដោយ។ គេអាចឃើញមាន អង្គការរដ្ឋជាច្រើនដែលធ្វើការងារទាក់ទងនឹងការអប់រំ ដែលផ្អែកលើសិទ្ធិមនុស្ស។ ឧទាហរណ៏ អាចមានគណៈកម្មាធិការទទួលបន្ទុកការអប់រំ អង្គការទទួលបន្ទុកសិទ្ធិកុមារ អង្គការទទួលបន្ទុកយេនឌ័រ និងអង្គការទទួលបន្ទុកសិទ្ធិមនុស្សទូទៅ។

5 កំណត់សំគាល់ : អាយុជាក់លាក់ត្រូវបានកំណត់សំរាប់ការអប់រំ បើសិនជារដ្ឋាភិបាលនីមួយៗបានរាយការណ៏ថាការអប់រំគឺជាកាតព្វកិច្ចដែលខានមិនបានរបស់កុមាររហូតដល់អាយុកំណត់ណាមួយនោះ កំណត់សំគាល់នឹងត្រូវផ្តល់ជូននៅក្នុងប្រទេសដែលការអប់រំមិនមែនជាភារកិច្ចដែលខានមិនបានរបស់កុមារ និងអាយុត្រូវឈប់រៀនមិនត្រូវបានកំណត់។ អាយុអប្បបរមាសំរាប់ធ្វើការហាក់ដូចជាបានបញ្ជាក់យ៉ាងច្បាស់ដោយភាគីរដ្ឋនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារដែលបកស្រាយនៅខាងក្រោម។ អាយុអប្បបរមាមិនត្រូវបានកំណត់ទេនៅក្នុងប្រទេសមួយចំនួន ជាពិសេសសំរាប់ពួកជនជាតិភាគតិច។ អាយុអប្បបរមាសំរាប់ពិរុទ្ធជនហាក់ដូចជាតិចណាស់ ហើយកុមារអាចនឹងត្រូវចោទប្រកាន់ពីបទអ្វីមួយ បើទោះជាគេទើបតែចាប់ផ្តើមរៀននៅបឋមសិក្សាក៏ដោយ។

ក្របខ័ណ្ឌស្ថាប័នទាំងនេះអាចនឹងធ្វើឲ្យការអប់រំផ្អែកលើសិទ្ធិមនុស្សមានលក្ខណៈងាយស្រួលផង និងលំបាកផង។ អង្គការរដ្ឋជាច្រើនអាចផ្តល់ជាពុទ្ធិចំរុះដែលអាចយកទៅបញ្ចូលនៅក្នុងយុទ្ធសាស្ត្រពិស្តារមួយ។ ផ្ទុយទៅវិញ យុទ្ធសាស្ត្រពិស្តារមួយអាចបង្កការលំបាកក្នុងការបង្កើត ដោយសារតែការមិនឯកភាពគ្នារបស់ស្ថាប័នរដ្ឋទាំងនេះ ដោយសារស្ថាប័ននីមួយៗមានរបៀបវារៈរៀងៗខ្លួន និងមានការទទួលខុសត្រូវមានកំរិត។